Manulife

# **អតិថិជនជាទីគោរព!**

*[English Below]*

ចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២៦ ក្រុមហ៊ុន មេនូឡាយហ្វ៍ (ខេមបូឌា) ភីអិលស៊ី (ហៅកាត់ថា «ក្រុមហ៊ុន» ឬ «មេនូឡាយហ្វ៍») នឹងធ្វើបច្ចុប្បន្នភាពសាខាក្រុមហ៊ុនដោយនាំយកប្រតិបត្តិការសេវាកម្មនៅតាមសាខានានា មកកាន់ការិយាល័យកណ្តាលរាជធានីភ្នំពេញ និងការិយាល័យសាខាខេត្តសៀមរាប។

**ជាមួយគ្នានេះ តំណាងផ្នែកលក់ទូទាំងប្រទេសរបស់ក្រុមហ៊ុន បន្តផ្តល់ជំនួបជាមួយអតិថិជនដោយផ្ទាល់តាមការស្នើសុំណាត់ជួបផ្តល់សេវាកម្មនានាពីអតិថិជនផងដែរ។**

ដោយឡែក អតិថិជនក៏អាចប្រើកម្មវិធីទូរសព្ទរបស់ មេនូឡាយហ្វ៍ ឬទូរសព្ទមកកាន់សេវាបម្រើអតិថិជនដោយ ឥតគិតថ្លៃរៀងរាល់ម៉ោងធ្វើការ ដើម្បីដាក់ពាក្យទាមទារសំណង ពិនិត្យបណ្ណសន្យារ៉ាប់រង បង់បុព្វលាភធានារ៉ាប់រង ធ្វើបច្ចុប្បន្នភាពព័ត៌មានផ្ទាល់ខ្លួន និងចូលមើលឯកសារបណ្ណសន្យារ៉ាប់រងជាដើម។ ខាងក្រោមនេះ គឺជាវិធីដែល អតិថិជនកំពុងប្រើប្រាស់សម្រាប់សេវាកម្មនានា៖

- កម្មវិធីទូរសព្ទ Manulife Cambodia App



ស្កេនដើម្បីទាញយកកម្មវិធី

- លេខទូរសព្ទផ្នែកសេវាបម្រើអតិថិជន (ឥតគិតថ្លៃ)៖ 1800 211 211
- អ៊ីមែល៖ customer_service_kh@manulife.com
- ការអញ្ជើញមកកាន់ការិយាល័យកណ្តាលរាជធានីភ្នំពេញ ឬសាខាខេត្តសៀមរាប

ការធ្វើបច្ចុប្បន្នភាពសាខាក្រុមហ៊ុននេះមិនប៉ះពាល់ដល់បណ្ណសន្យារ៉ាប់រង ទឹកប្រាក់ធានារ៉ាប់រង ឬអត្ថប្រយោជន៍បណ្ណសន្យារ៉ាប់រងអតិថិជនឡើយ។ ក្រុមហ៊ុននៅតែបន្តពង្រឹងគុណភាពសេវាកម្មជូនអតិថិជនដោយយកចិត្តទុក ដាក់ និងឆាប់រហ័ស ដោយផ្អែកលើគោលការណ៍ «អតិថិជនជាចម្បង» ជានិច្ច។

គួរបញ្ជាក់ផងដែរថា ក្រុមហ៊ុន បានកំពុងបម្រើអតិថិជននៅកម្ពុជាសរុបជាង **222,000** នាក់ ហើយយើងនៅតែប្តេជ្ញា គាំទ្រអតិថិជន ក៏ដូចជាគ្រួសារកម្ពុជាជាច្រើនរូបទៀត នូវដំណោះស្រាយហិរញ្ញវត្ថុ និងការការពារជូនលោក អ្នក និងមនុស្សជាទីស្រលាញ់។

សូមថ្លែងអំណរគុណសម្រាប់ការបន្តគាំទ្រ និងផ្តល់ទំនុកចិត្តមកលើ ក្រុមហ៊ុន មេនូឡាយហ្វ៍។

Manulife

## កម្រងសំណួរ - ចម្លើយ សម្រាប់អតិថិជន

| **សំណួរ** | **ចម្លើយ** |
|---|---|
| ១.តើអតិថិជនអាចប្រើប្រាស់វិធីអ្វីខ្លះ (ដែលចំណេញពេលវេលា និងប្រសើរជាងមុន) សម្រាប់សេវាកម្មនានានៃបណ្ណសន្យារ៉ាប់រងរបស់គាត់ (ដោយពុំចាំបាច់មកកាន់សាខាផ្ទាល់)? | អតិថិជនអាចប្រើប្រាស់វិធីខាងក្រោមសម្រាប់សេវាកម្មនានារបស់ មេនូឡាយហ្វ៍ បានយ៉ាងរលូន ដោយគ្មានការរំខាន តាមរយៈ៖<br>▪ ផ្នែកសេវាបម្រើអតិថិជន (ឥតគិតថ្លៃ)៖ 1800 211 211<br>▪ កម្មវិធីទូរសព្ទ Manulife Cambodia App និងទំព័រហ្វេសប៊ុកផ្លូវការរបស់ ក្រុមហ៊ុន (Manulife Cambodia Facebook Messenger)<br>▪ តំណាងផ្នែកលក់ទូទាំងប្រទេស<br>▪ អ៊ីមែល៖ customer_service_kh@manulife.com<br>អតិថិជននៅតែអាចអញ្ជើញមកកាន់ការិយាល័យកណ្តាលរាជធានីភ្នំពេញ ឬការិយាល័យសាខាខេត្តសៀមរាប សម្រាប់សេវាកម្មនានារបស់ មេនូឡាយហ្វ៍ ដូចគ្នា។ |
| ២.តើអតិថិជនអាចបង់បុព្វលាភរ៉ាប់រងបានដោយរបៀបណា ដោយពុំចាំបាច់មកកាន់សាខាផ្ទាល់? | អតិថិជនអាចធ្វើការបង់បុព្វលាភរ៉ាប់រងបានយ៉ាងងាយស្រួល និងមានសុវត្ថិភាព តាមរយៈជម្រើសដូចខាងក្រោមដែលផ្លូវការ និងបានអនុម័តដោយក្រុមហ៊ុន៖<br>▪ កម្មវិធីទូរសព្ទ Manulife Cambodia App<br>▪ កម្មវិធីទូរសព្ទរបស់ធនាគារដៃគូ<br>▪ ភ្នាក់ងារ វីង (WING) ទូទាំងប្រទេស<br>▪ ការផ្ទេរប្រាក់តាមធនាគារ<br>ស្វែងយល់បន្ថែមពីរបៀបបង់បុព្វលាភធានារ៉ាប់រង តាមរយៈ https://bit.ly/4olZn3N ឬទាក់ទងមកកាន់ 1800 211 211 (ដោយឥតគិតថ្លៃ)។ |
| ៣.តើអតិថិជនអាចស្នើសុំសេវាកម្មពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រងរបស់គាត់ ឬផ្លាស់ប្តូរព័ត៌មានផ្សេងៗ បានដោយរបៀបណា? | អតិថិជនអាចស្នើសុំសេវាកម្មពាក់ព័ន្ធនឹងបណ្ណសន្យារ៉ាប់រង ឬផ្លាស់ប្តូរព័ត៌មានបាន តាមរយៈជម្រើសដូចខាងក្រោម៖<br>▪ កម្មវិធីទូរសព្ទ Manulife Cambodia App<br>▪ ផ្នែកសេវាបម្រើអតិថិជន (ឥតគិតថ្លៃ)៖ 1800 211 211<br>▪ តំណាងផ្នែកលក់ទូទាំងប្រទេស<br>▪ អ៊ីមែល៖ customer_service_kh@manulife.com<br>សេវាកម្មរួមមាន៖<br>▪ កែប្រែព័ត៌មានផ្ទាល់ខ្លួន<br>▪ ពិនិត្យមើលព័ត៌មានបណ្ណសន្យារ៉ាប់រង<br>▪ ទាញយកឯកសារកិច្ចសន្យាធានារ៉ាប់រង<br>សេវាកម្មទាំងនេះអាចធ្វើបានយ៉ាងរហ័ស និងងាយស្រួល តាមរយៈកម្មវិធីទូរសព្ទ Manulife Cambodia App។ |

| | |
|---|---|
| ៤.តើអតិថិជនអាចដាក់ពាក្យទាមទារសំណង ឬតាមដានដំណើរការនៃសំណើទាមទារសំណង បានដោយរបៀបណា? | អតិថិជនអាចដាក់ពាក្យទាមទារសំណង តាមរយៈជម្រើសដូចខាងក្រោម៖<br>▪ គេហទំព័រទាមទារសំណងផ្លូវការរបស់ក្រុមហ៊ុន តាមរយៈតំណភ្ជាប់នេះ "សេវាកម្មទាមទារសំណង"<br>▪ កម្មវិធីទូរសព្ទ Manulife Cambodia App<br>▪ តំណាងផ្នែកលក់ទូទាំងប្រទេស<br>▪ ផ្នែកសេវាបម្រើអតិថិជន (ឥតគិតថ្លៃ)៖ 1800 211 211<br>ដំណើរការរទាមទារសំណង និងស្តង់ដារសេវាកម្មមិនមានការផ្លាស់ប្តូរទេ។ អតិថិជននឹងទទួលបានការណែនាំ ធ្វើបច្ចុប្បន្នភាព និងតាមដានដំណើរការទាមទាសំណងឱ្យទាន់ពេលវេលាតាមរយៈទូរសព្ទ អ៊ីម៉ែល និងកម្មវិធីទូរសព្ទរបស់ មេនូឡាយហ្វ៍។ ដើម្បីទទួលបានការធ្វើបច្ចុប្បន្នភាពឆាប់រហ័ស និងកាន់តែងាយស្រួល យើងខ្ញុំ លើកទឹកចិត្តអតិថិជនឱ្យប្រើប្រាស់កម្មវិធីទូរសព្ទរបស់ មេនូឡាយហ្វ៍ Manulife Cambodia App។ |
| ៥.តើការធ្វើបច្ចុប្បន្នភាពសាខាខាងលើនឹងមានផលប៉ះពាល់ដល់បណ្ណសន្យារ៉ាប់រង ឬអត្ថប្រយោជន៍ណាមួយរបស់អតិថិជនដែរឬទេ? | មិនប៉ះពាល់ទេ។<br>បណ្ណសន្យារ៉ាប់រង និងកិច្ចសន្យាធានារ៉ាប់រងទាំងអស់របស់អតិថិជន មិនថាអតិថិជននៅទីណាក៏ដោយ នៅតែមានសុពលភាពពេញលេញ ហើយអត្ថប្រយោជន៍ និងកាតព្វកិច្ចក្រោមបណ្ណសន្យារ៉ាប់រងមិនមានការផ្លាស់ប្តូរឡើយ។ |
| ៦.តើមានការផ្តល់សេវាកម្មដោយផ្ទាល់ដល់អតិថិជនដែរឬទេ? | បាទ/ចាស មាន។ តំណាងផ្នែកលក់របស់យើងនៅទូទាំងប្រទេស អាចជួបអតិថិជនដោយផ្ទាល់ដើម្បីផ្តល់សេវាកម្មតាមរយៈការណាត់ជួប ដើម្បីធានាថា អតិថិជននៅតែអាចទទួលបានការគាំទ្រផ្ទាល់នៅពេលដែលអតិថិជនមានតម្រូវការ។<br>អតិថិជនអាចទាក់ទងតំណាងផ្នែកលក់របស់ខ្លួនដោយផ្ទាល់ ឬឆែកលេខទូរសព្ទតំណាងផ្នែកលក់ តាមរយៈកម្មវិធីទូរសព្ទ Manulife Cambodia App។<br>អតិថិជនក៏អាចទូរសព្ទមកកាន់ផ្នែកសេវាបម្រើអតិថិជន (1800 211 211) ដើម្បីទទួលបានជំនួយបន្ថែម ហើយក៏អាចអញ្ជើញមកកាន់ការិយាល័យកណ្តាលរាជធានីភ្នំពេញ ឬការិយាល័យសាខាខេត្តសៀមរាបផ្ទាល់ផងដែរ។ |
| ៧. តើអ្វីជាការប្តេជ្ញាចិត្តរបស់មេនូឡាយហ្វ៍ ចំពោះអតិថិជនក្នុងអំឡុងពេលនេះ? | ក្រុមហ៊ុន មេនូឡាយហ្វ៍ នៅតែបន្តប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្តល់សេវាកម្មដល់អតិថិជន ដោយយកចិត្តទុកដាក់ ប្រកបដោយគុណភាព វិជ្ជាជីវៈ និងបន្តយ៉ាង ជាប់លាប់។ ទោះជាមានការផ្លាស់ប្តូរណាមួយ ក៏ស្តង់ដារសេវាកម្ម និងការប្តេជ្ញាចំពោះអតិថិជននៅដដែល ដោយផ្អែកលើគោលការណ៍ «អតិថិជនជាចម្បង»។<br>ក្រុមហ៊ុនបន្តទំនាក់ទំនងជាមួយអតិថិជនយ៉ាងជិតស្និត ដើម្បីគាំទ្រលោកអ្នកតាមរយៈបណ្តាញទំនាក់ទំនងផ្លូវការនានារបស់ ក្រុមហ៊ុន ដូចដែលបានជម្រាបជូនខាងលើ។ |
| ៨.តើអតិថិជននៅក្រៅរាជធានីភ្នំពេញ ឬខេត្តសៀមរាបនៅតែទទួលបានការគាំទ្រ និងគុណភាពសេវាកម្មដូចគ្នា<br>ដែរឬទេ? | បាទ/ចាស សេវាកម្មរបស់យើងខ្ញុំគ្របដណ្តប់ទូទាំងប្រទេស។<br>អតិថិជនទាំងអស់អាចទូរសព្ទមកកាន់ផ្នែកសេវាបម្រើអតិថិជន 1800 211 211 ដោយឥតគិតថ្លៃ ពីគ្រប់ទីកន្លែង។ តំណាងផ្នែកលក់របស់យើងមានប្រចាំការនៅតាមបណ្តាលខេត្តនានា ហើយលោកអ្នកអាចប្រើប្រាស់សេវាកម្មឌីជីថលរបស់ ក្រុមហ៊ុន បាន ២៤ម៉ោង ក្នុង១ថ្ងៃ និង៧ថ្ងៃ ក្នុង១សប្តាហ៍ នៅគ្រប់ទីកន្លែងដែលមានសេវាអ៊ីនធឺណែត។ |